**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ១៧ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការ
## ត្រួតពិនិត្យការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ស ម្រេ ច**

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យ ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាលហៅកាត់ថា " គ.ត.អ.ល. "។ គ.ត.អ.ល.ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ២.-**

គ.ត.អ.ល. មានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ឃឹម បូរ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម ឆេង សារឿន | រដ្ឋលេខាធិការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| ៣- ឯកឧត្តម កែវ សាផល | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |

Downloaded from http://www.khmerlaws.com

៤- ឯកឧត្តម ឆាយ់ ចន្ទតារា មេធាវីរាជរដ្ឋាភិបាល សមាជិក

៥- ឯកឧត្តម ស៊ូរ គីមអាន អគ្គលេខាធិការរងរាជរដ្ឋាភិបាល សមាជិក

៦- ឯកឧត្តម លឹម អេង សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

៧- ឯកឧត្តម ឈួរ រស្មីឫទ្ធិ អគ្គនាយកអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

៨- លោក ឌួច សារិន ប្រធាននាយកដ្ឋានរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩- លោក ស៊ឹម សាន ប្រធាននាយកដ្ឋានពាណិជ្ជកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១០- លោក ឃុយ ហៀង ប្រធាននាយកដ្ឋានគមនាគមន៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១១- លោក ឡុង សុខា ប្រធាននាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១២- លោក អ៊ិត ស៊ុណាត ប្រធានផ្នែកទទួលបន្ទុកសំណួរ-ចម្លើយសភា នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

១៣- លោក វ៉ូក ចាន់ណារិទ្ធ ប្រធាននាយកដ្ឋានទំនាក់ទំនងអធិការកិច្ចតាមបណ្តាស្ថាប័ននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

១៤- លោក ឡុក ស៊ីណា អនុប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

១៥- លោក ងាក់ ម៉េងអ៊ិយ អនុប្រធាននាយកដ្ឋានតាមដានការអនុវត្តច្បាប់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

១៦- លោក ហេង ចាន់ឌី អនុប្រធាននាយកដ្ឋានអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច សមាជិក

១៧- លោក ងៃ វ៉ាន់ឆន អនុប្រធាននាយកដ្ឋានឧស្សាហកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៨- លោក ឆា លាងហ៊ត ជំនួយការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល សមាជិក និងជាប្រធានលេខាធិការដ្ឋាន

## ប្រការ ៣.-

គណៈកម្មាធិការនេះមានតួនាទី ជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និងមានភារកិច្ចដូចតទៅ ៖

-ធ្វើបញ្ជីសម្រង់រាល់លិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល

-តាមដានពិនិត្យការអនុវត្ត អនុក្រឹត្យ បទបញ្ជា សេចក្តីសម្រេច សារាចរ របស់រាជរដ្ឋាភិបាល និងសេចក្តីសម្រេចនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដោយសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរកឱ្យឃើញចំណុចខ្លាំង ចំណុចខ្សោយនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តទាំងនោះ

-កោះអញ្ជើញតំណាងក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ មកបំភ្លឺការអនុវត្តលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាល

Downloaded from http://www.khmerlaws.com

-ចុះពិនិត្យតាមដានដល់មូលដ្ឋាន ពាក់ព័ន្ធទៅនឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលក្នុងករណីចាំបាច់

-ទទួលភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៤.-**

គ.ត.អ.ល. មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ គ.ត.អ.ល. អាចតាំងក្រុមការងារដើម្បីចុះបំពេញភារកិច្ចតាមការចាំបាច់ និងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធចូលរួមក្នុងប្រតិបត្តិការ ។

**ប្រការ ៥.-**

សមាជិក គ.ត.អ.ល. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៦.-**

គ.ត.អ.ល. មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាជំនួយការដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី ។ លេខាធិការដ្ឋាននេះដឹកនាំដោយប្រធានមួយរូប និងមានមន្ត្រីក្របខ័ណ្ឌរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចមួយចំនួន ជាជំនួយការតាមការចាំបាច់របស់ គ.ត.អ.ល ។

**ប្រការ ៧.-**

សេចក្តីសម្រេចលេខ ៣៦ សសរ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមការងារសម្រាប់ត្រួតពិនិត្យឃ្លាំមើលទៅលើសកម្មភាព និងលទ្ធផលអនុវត្តការងាររបស់ក្រសួង ស្ថាប័ន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី ខេត្ត ក្រុង ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មករា ឆ្នាំ ២០០៩

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៨
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

Downloaded from http://www.khmerlaws.com